**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០១៣/០៨/២០០៨ កបធ.សជណ　　　　　　　　　　រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០០៨

**ជម្រាបមក**

**លោក មាស ខេង**

**សមាជិកគណៈកម្មាធិការនាយកគណបក្ស សម រង្ស៊ី ខេត្តស្វាយរៀង**

**កម្មវត្ថុ** : រឿងទាក់ទងនឹងបណ្តឹងរបស់លោក មាស ខេង ប្តឹងបដិសេធ ការចារបដិសេធរបស់ **PEC** ខេត្តស្វាយរៀង លេខ ០០៩/០៨ និង លេខ ០១០/០៨ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៨

**យោង** : បណ្តឹងគ្មានលេខ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៨ របស់លោក មាស ខេង តំណាងឱ្យលោក សេង ម៉ារឌី ប្រធានក្រុមការងារគណបក្ស សម រង្ស៊ី ខេត្តស្វាយរៀង

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបមក លោក មាស ខេង ជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើបណ្តឹងរបស់លោករួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកបណ្តឹងនេះមកពិភាក្សា និង សម្រេចបានឡើយ ពីព្រោះបណ្តឹងរបស់លោកមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ២៥ថ្មី មាត្រា ២៦ និងមាត្រា ២៧ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង មាត្រា ៧៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**